**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

លេខ ០១១ សសរ.កសក

# សេចក្តីសម្រេច

## ស្តីពី

## ការកែសម្រួលសមាសភាពគណៈកម្មាធិការប្រឹក្សាយោបល់សម្រាប់ការផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអនុគណៈកម្មាធិការបច្ចេកទេសកសិកម្ម រុក្ខាប្រមាញ់ និងនេសាទថ្នាក់ជាតិ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការ និងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលម្អដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការកែសម្រួលមាត្រា២ មាត្រា២៥ មាត្រា២៦ និងមាត្រា៣៥ នៃអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ និងមាត្រា២៧ថ្មី នៃអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៧
- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្តីពីការដំឡើងនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល ទៅជាអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**ប្រការ១.**_

ត្រូវបានកែសម្រួលសមាសភាពគណៈកម្មាធិការប្រឹក្សាយោបល់សម្រាប់ការផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម **ហ៊ីត មិនណារី** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រធាន |
| ២. | ឯកឧត្តម **ចាន់ សារុន្ធ** | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៣. | ឯកឧត្តម **អេង ជាសាន** | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល , | សមាជិក |
| ៤. | ឯកឧត្តម **ប៉ុល សុផា** | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានកៅស៊ូ | សមាជិក |
| ៥. | ឯកឧត្តម **កែវ អូម៉ាលីស្ស** | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានរដ្ឋបាលព្រៃឈើ | សមាជិក |
| ៦. | ឯកឧត្តម **ចិន ឆាយ** | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម | សមាជិក |
| ៧. | ឯកឧត្តម **តាន់ ផាន់ណារ៉ា** | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ | សមាជិក |
| ៨. | ឯកឧត្តម **ង៉ោ ប៊ុនថាន** | សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម | សមាជិក |
| ៩. | ឯកឧត្តម **ស្ងួន សេរី** | នាយកវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម | សមាជិក |
| ១០. | ឯកឧត្តម **ឆន់ វឌ្ឍនា** | នាយកវិទ្យាស្ថានជាតិកសិកម្មព្រែកលៀប | សមាជិក |
| ១១. | លោកឧកញ៉ា **លឹម ហេង** | អនុប្រធានសភាពាណិជ្ជកម្មកម្ពុជា | សមាជិក |
| ១២. | លោក **សរ ចិត្រា** | អគ្គលេខាធិការរងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៣. | លោក **ម៉ៅ មិនា** | ប្រធាននាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់និងនេសាទ | សមាជិកអចិន្ត្រៃយ៍ |
| ១៤. | លោក **ទី ចាន់ណា** | ប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស | សមាជិក |
| ១៥. | លោក **ម៉ក់ ម៉ូនី** | ប្រធាននាយកដ្ឋានផែនការ និងស្ថិតិ | សមាជិក |
| ១៦. | លោក **គង់ តាដ** | ប្រធាននាយកដ្ឋានកសិ-ឧស្សាហកម្ម | សមាជិក |
| ១៧. | លោក **អ៊ុក ម៉ាករា** | នាយកវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា | សមាជិក |
| ១៨. | លោក **យ៉ៅ វេន** | ប្រធានមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម | សមាជិក |
| ១៩. | លោកស្រី **សុខ សុទ្ធាវី** | ប្រធានរដ្ឋបាលសភាពាណិជ្ជកម្មកម្ពុជា | សមាជិកា |
| ២០. | លោក **ជា សុខុន** | អនុប្រធាននាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | លេខាធិការ |
| ២១. | កញ្ញា **ឡាយ លីនី** | មន្ត្រីនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | លេខាធិការ។ |

**ប្រការ២.**_

គណៈកម្មាធិការនេះមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- គាំទ្រ និងសម្របសម្រួលសកម្មភាព និងទំនាក់ទំនងរវាងអង្គភាពស្រាវជ្រាវ អង្គភាពផ្សព្វផ្សាយ និងអង្គភាពបណ្តុះបណ្តាលកសិកម្ម ឱ្យមានប្រសិទ្ធភាព
- ជំរុញ និងគាំទ្រការអនុវត្តគោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជាឱ្យមានប្រសិទ្ធភាព
- កៀរគរធនធាន និងថវិកាគាំទ្រដល់កម្មវិធី គម្រោង និងសកម្មភាពផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនានានៅកម្ពុជា
- ពិនិត្យ និងសម្រេចលើកម្មវិធីអភិវឌ្ឍន៍ធនធានមនុស្ស ផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កម្មវិធីសិក្សាការបណ្តុះបណ្តាលមន្ត្រី និងភ្នាក់ងារផ្សព្វផ្សាយ

- ពិនិត្យ និងសម្រេចលើគោលការណ៍ណែនាំ ប្រធានបទ កម្មវត្ថុ ឯកសារ សម្ភារ និងឯកសារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ពិនិត្យ និងសម្រេចលើមធ្យោបាយ វិធីសាស្ត្រ និងសេវាផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ពិនិត្យ និងសម្រេចលើរបាយការណ៍តាមដាន និងវាយតម្លៃរាល់សកម្មភាពផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលអនុវត្តដោយវិស័យសាធារណៈ វិស័យឯកជន និងដៃគូអភិវឌ្ឍន៍នានា
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលពាក់ព័ន្ធនឹងការងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទតាមការចាំបាច់។

**ប្រការ៣._**

ត្រូវបានកែសម្រួលសមាសភាពអនុគណៈកម្មាធិការបច្ចេកទេសកសិកម្ម រុក្ខាប្រមាញ់ និងនេសាទថ្នាក់ជាតិ ដែលស្ថិតនៅក្រោមគណៈកម្មាធិការប្រឹក្សាយោបល់សម្រាប់ការផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម **ចាន់ សារុន្ធ** | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រធាន |
| ២. | លោកឧកញ៉ា **លឹម ហេង** | អនុប្រធានសភាពាណិជ្ជកម្មកម្ពុជា | អនុប្រធាន |
| ៣. | លោក **ម៉ុន រ័ត្ន** | អគ្គលេខាធិការរងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៤. | លោក **ម៉ៅ មិនា** | ប្រធាននាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធានអចិន្ត្រៃយ៍ |
| ៥. | លោក **ម៉ាក់ សឿន** | អគ្គនាយករងនៃអគ្គនាយកដ្ឋានកសិកម្ម | សមាជិក |
| ៦. | លោកស្រី **ខេង សុបញ្ញា** | អនុប្រធានរដ្ឋបាលព្រៃឈើ | សមាជិកា |
| ៧. | លោកស្រី **គាំង ឃីម** | អនុប្រធានរដ្ឋបាលជលផល | សមាជិកា |
| ៨. | លោក **គឹម សាវឿន** | អគ្គនាយករងនៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ | សមាជិក |
| ៩. | លោក **អួន សុវណ្ណ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានកៅស៊ូ | សមាជិក |
| ១០. | លោក **ម៉ុនតុង បូរារិន** | នាយកផ្នែកស្រាវជ្រាវ និងផ្សព្វផ្សាយនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម | សមាជិក |
| ១១. | លោក **សំ សំអាន** | នាយករងវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម | សមាជិក |
| ១២. | លោក **ភាយ គាំងមាន** | នាយករងវិទ្យាស្ថានជាតិកសិកម្មព្រែកលៀប | សមាជិក |
| ១៣. | លោក **ហេង ម៉ុននី** | អនុប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស | សមាជិក |
| ១៤. | លោក **ហុក គឹមធួន** | អនុប្រធាននាយកដ្ឋានផែនការ និងស្ថិតិ | សមាជិក |
| ១៥. | លោក **ជា ពិសី** | អនុប្រធាននាយកដ្ឋានកសិ-ឧស្សាហកម្ម | សមាជិក |
| ១៦. | លោក **ឡោ ម៉ុណ្ណា** | នាយករងវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា | សមាជិក |
| ១៧. | លោក **មឿង សុនិត្យា** | អនុប្រធានមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម | សមាជិក |
| ១៨. | លោកស្រី **ហ៊ូ សុពណ៌** | អនុប្រធាននាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | លេខាធិការ |
| ១៩. | លោកស្រី **ស៉េ សុលីណា** | អនុប្រធានការិ.នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | លេខាធិការ។ |

**ប្រការ៤._**

អនុគណៈកម្មាធិការនេះមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- តាមដានការអនុវត្ត ការទទួលយក និងសាយភាយបច្ចេកវិទ្យាដែលបានធ្វើការផ្សព្វផ្សាយដោយវិស័យសាធារណៈ វិស័យឯកជន និងដៃគូអភិវឌ្ឍន៍នានា
- ដឹកនាំនិងសម្របសម្រួលជាមួយអង្គភាពជំនាញពាក់ព័ន្ធដើម្បីចងក្រង និងវាយតម្លៃលើឯកសារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- សម្របសម្រួល និងរៀបចំប្រជុំត្រួតពិនិត្យលើគុណវុឌ្ឍិនៃការងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- ត្រួតពិនិត្យ និងវាយតម្លៃលើគោលការណ៍ណែនាំ បទដ្ឋានអនុវត្តបច្ចេកវិទ្យា ការផ្សព្វផ្សាយ និងអភិវឌ្ឍន៍បច្ចេកវិទ្យាថ្មីៗ
- ពិនិត្យ ផ្តល់អនុសាសន៍ និងកែសម្រួលលើកម្មវត្ថុ ឯកសារ សម្ភារ មធ្យោបាយ វិធីសាស្ត្រ និងសេវាផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ទទួលចម្លើយតបពីអ្នកអនុវត្តដើម្បីសិក្សាបន្ត និងអភិវឌ្ឍន៍បច្ចេកវិទ្យាស្របតាមតម្រូវការរបស់កសិករ និងទីផ្សារ
- រៀបចំ កសាងលើកម្មវត្ថុ ប្រធានបទ ការស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យាថ្មីៗសម្រាប់ផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ពិនិត្យ សម្របសម្រួលកំណត់កម្មវិធីអភិវឌ្ឍន៍ធនធានមនុស្សសម្រាប់ផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- រៀបចំបូកសរុបរបាយការណ៍នៃកិច្ចប្រជុំពាក់ព័ន្ធ និងរបាយការណ៍វឌ្ឍនភាពពីសកម្មភាព កម្មវិធី និងគម្រោងផ្សព្វផ្សាយនានាដាក់ជូនគណៈកម្មាធិការប្រឹក្សាយោបល់សម្រាប់ការផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពិនិត្យ និងសម្រេច
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលពាក់ព័ន្ធនឹងការងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទតាមការចាំបាច់។

**ប្រការ៥.**_

សមាជិកគណៈកម្មាធិការ និងអនុគណៈកម្មាធិការខាងលើ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

**ប្រការ៦.**_

សេចក្តីសម្រេចលេខ ៤៥៩ សសរ.កសក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៦ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ៧.**_

អគ្គលេខាធិការ អគ្គាធិការ ប្រធាននាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រធានគ្រប់អង្គភាពដែលពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីខេត្ត និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៥រោច ខែ បុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០២០

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៧
- ឯកសារ កាលប្បវត្តិ